# ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២/០២/២០០៥ ស្តីពីការកែសម្រួលមាត្រា ១០ មាត្រា ១១ មាត្រា ១៤ មាត្រា ១៥ និងមាត្រា១៦នៃព្រះរាជក្រឹត្យ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៥ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩/ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

### មាត្រា មួយ.

មាត្រា ១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ត្រូវបានកែសម្រួល ដូចខាងក្រោម ៖

### មាត្រា ១០ថ្មី

**គ.ទ.ក** មានសមាជិកអចិន្ត្រៃយ៍ និងសមាជិកជ្រើសតាំង ។

**ក. សមាជិកអចិន្ត្រៃយ៍**

សមាជិកអចិន្ត្រៃយ៍រួមមាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ។ ឥស្សរជនទាំងពីររូបត្រូវធ្វើ ជាប្រធាន ឬអនុប្រធាន **គ.ទ.ក** ។ ឥស្សរជនដែលមានតំណែងខ្ពស់ជាងក្នុងរាជរដ្ឋាភិបាល ត្រូវធ្វើជាប្រធាន **គ.ទ.ក** ហើយឥស្សរជន ដែលមានតំណែងទាបជាងត្រូវធ្វើជាអនុប្រធាន **គ.ទ.ក** ។ ក្នុងករណីដែលឥស្សរជនទាំងពីររូប មានតំណែងស្មើគ្នាក្នុងរាជរដ្ឋាភិបាល ប្រធាន **គ.ទ.ក** ត្រូវជ្រើសរើសតាមរយៈពេលការបោះឆ្នោត របស់សមាជិកជ្រើសតាំងទាំងប្រាំរូប ដោយសំឡេងភាគច្រើនដាច់ខាត ហាសិប បូក មួយ ។

**ខ. សមាជិកជ្រើសតាំង**

សមាជិកជ្រើសតាំងមានប្រាំរូប ដែលត្រូវជ្រើសរើសចេញពីឥស្សរជនកម្ពុជាដែលមានសញ្ញាប័ត្រឧត្តមសិក្សា និងមានជំនាញផ្នែកគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ឬមានជំនាញក្នុងកសាងគោលនយោបាយ ផ្នែកឧត្តមសិក្សា តាមរយៈនីតិវិធីដូចបានកំណត់ក្នុងមាត្រា ១៤ថ្មី និង១៦ថ្មី នៃព្រះរាជក្រឹត្យនេះ ឬមាត្រា៦២ នៃព្រះរាជក្រឹត្យលេខនស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការ

ទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ។

**គ.ទ.ក** មានជំនាញពីររូប ដែលមានបទពិសោធន៍នៅក្នុងស្ថាប័នទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សានៃប្រទេសនានាជាទីប្រឹក្សា ។

**មាត្រា ១១ថ្មី**

សមាជិក **គ.ទ.ក** ទាំងអស់ត្រូវជ្រើសតាំងឱ្យបម្រើការងារមិនពេញម៉ោង និងទទួលប្រាក់ឧបត្ថម្ភតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។ ប្រាក់ឧបត្ថម្ភរបស់សមាជិក **គ.ទ.ក** ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ប្រធាន **គ.ទ.ក** ។

**គ.ទ.ក** មានអគ្គលេខាធិការដ្ឋានមួយចំណុះផ្ទាល់ទីស្តីការគណៈរដ្ឋមន្ត្រី ។ អគ្គលេខាធិការដ្ឋាន **គ.ទ.ក** ដឹកនាំដោយអគ្គលេខាធិការ១រូបមានឋានៈស្មើអនុរដ្ឋលេខាធិការ និងអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ ។ សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋាននៃ **គ.ទ.ក** នឹងកំណត់ដោយអនុក្រឹត្យ ។

**គ.ទ.ក** មានបទបញ្ជាផ្ទៃក្នុង ឡូហ្គោ និងត្រាមួយដោយឡែករបស់ខ្លួន ។

**មាត្រា ១៤ ថ្មី.**

ដើម្បីជ្រើសតាំងសមាជិក **គ.ទ.ក** ប្រធាន **គ.ទ.ក** ត្រូវបង្កើតគណៈកម្មការស្នើតាំងមួយសម្រាប់ជ្រើសតាំងបេក្ខភាពតំណាងសមាជិក **គ.ទ.ក** ។ ដើម្បីឱ្យដំណើរការជ្រើសតាំងនេះ ប្រព្រឹត្តទៅបានប្រសិទ្ធភាពខ្ពស់ ប្រធាន **គ.ទ.ក** ត្រូវជូនដំណឹងទៅគណៈកម្មការស្នើតាំងឱ្យធ្វើការស្នើតាំងបេក្ខជនសម្រាប់តំណែងសមាជិក **គ.ទ.ក** ។

**មាត្រា ១៥. ថ្មី**

ក្នុងការជ្រើសតាំង បេក្ខភាពតំណែងសមាជិក **គ.ទ.ក** គណៈកម្មការស្នើតាំង ត្រូវធ្វើការជ្រើសតាំងតាមរយៈការបោះឆ្នោត ដោយយកសំឡេងភាគច្រើនដាច់ខាត ហាសិប បូក មួយ ។ បន្ទាប់មក គណៈកម្មការនេះ ត្រូវបញ្ជូនបញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតប្រាំរូបទៅ ប្រធាន **គ.ទ.ក** ។ ផ្អែកលើបញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតនោះ ប្រធាន **គ.ទ.ក** ត្រូវរៀបចំស្នើតែងតាំង សមាជិក **គ.ទ.ក** ដោយព្រះរាជក្រឹត្យ ។ គណៈកម្មការស្នើតាំង ក៏មានភារកិច្ចធ្វើការស្នើតាំងសមាសភាពថ្មីផងដែរ ពេលណាតំណែងនៃសមាជិក**គ.ទ.ក** ណាមួយដែលទំនេរ ។

**មាត្រា ១៦. ថ្មី**

សមាសភាពនៃគណៈកម្មការស្នើតាំងមានដូចតទៅ ៖

- តំណាងទីស្តីការគណៈរដ្ឋមន្ត្រីមួយរូប ........................................................................ ប្រធាន
- តំណាងក្រសួងអប់រំ យុវជន និងកីឡាមួយរូប ............................................................ អនុប្រធាន
- សកលវិទ្យាធិការ ឬព្រឹទ្ធបុរស ឬនាយកនៃគ្រឹះស្ថានឧត្តមសិក្សាដែលទទួលការអនុញ្ញាតជាផ្លូវការពីរាជរដ្ឋាភិបាលមួយរូប ........................................................................................................ សមាជិក
- តំណាងក្រសួងអាណាព្យាបាលនៃគ្រឹះស្ថានឧត្តមសិក្សានីមួយៗ .................................. សមាជិក

គណៈកម្មការស្នើតាំងមានសិទ្ធិអញ្ជើញឱ្យចូលរួមជាអ្នកអង្កេតការណ៍ ៖

- តំណាងម្ចាស់ជំនួយបរទេស ដែលនាំមុខគេផ្នែកឧត្តមសិក្សាបីរូប
- តំណាងមកពីភ្នាក់ងារសាកលវិទ្យាល័យប្រើភាសាបារាំង AUF បីរូប
- តំណាងមកពីបណ្តាញសមាគមសាកលវិទ្យាល័យអាស៊ាន ASEAN University Network មួយរូប
- តំណាងមកពីអង្គការស៊ីម៉េអូរ៉ាយហេត SEAMEO RIHED មួយរូប ។

**មាត្រា ពីរ.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា បី**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា បួន**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ។

ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។